**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
លេខ ១៣២ បទ.សសរ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣

# សេចក្តីសំរេច
## ស្តីពីការបែងចែកភារកិច្ច
## របស់ថ្នាក់ដឹកនាំនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ ៖** បែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សំដៅធានាការដឹកនាំកិច្ចការទូទៅរបស់ក្រសួង និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ ៖ រដ្ឋមន្ត្រី ៖** រដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំការងាររួមរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ចាត់ចែង និងបញ្ជារាល់សកម្មភាពលើគ្រប់វិស័យពាក់ព័ន្ធ និងដឹកនាំផ្ទាល់លើការងាររដ្ឋបាល, បុគ្គលិក និងបណ្តុះបណ្តាល, ផែនការហិរញ្ញវត្ថុ, អធិការកិច្ច និងសវនកម្មផ្ទៃក្នុង ។

**រដ្ឋលេខាធិការ ៖**

១- ឯកឧត្តម **សារ៉ាក់ ខាន់** : ទទួលបន្ទុកជារដ្ឋមន្ត្រីស្តីទី ពេលរដ្ឋមន្ត្រីអវត្តមាន តាមរយៈលិខិតប្រគល់សិទ្ធិ និងជួយរដ្ឋមន្ត្រីអំពីកិច្ចការនីតិកម្ម, ការងារអង្គភាពបញ្ញត្តិករទូរគមនាគមន៍កម្ពុជា (T.R.C) និងការងារហិរញ្ញវត្ថុ ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ, សៀមរាប, បន្ទាយមានជ័យ និងមណ្ឌលគីរី ។

២- ឯកឧត្តម **ខាយ ឃុនហេង** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីការងារផែនការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, កម្មវិធីវិនិយោគសាធារណៈ (P.I.P) និងការងារសវនកម្មផ្ទៃក្នុង ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម, ព្រៃវែង, ស្វាយរៀង និងរតនគីរី ។

៣- ឯកឧត្តម **ឯក វណ្ណឌី** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីគោលនយោបាយអភិវឌ្ឍវិស័យប្រៃសណីយ៍, ទំនាក់ទំនងអន្តរជាតិលើវិស័យប្រៃសណីយ៍ និងការងារអង្គភាពប្រៃសណីយ៍កម្ពុជា (C.P) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់, បាត់ដំបង, ប៉ៃលិន និងឧត្តរមានជ័យ ។

៤- លោកជំទាវ **រស់ សុរក្សា** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍, ការងារមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (D.M.C) និងកិច្ចការយេនឌ័រ (Gender) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល, តាកែវ, កំពត និងកែប ។

៥- ឯកឧត្តម **ភាន ច័ន្ទមេត្តា** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីការងារសហប្រតិបត្តិការអន្តរជាតិ និងការងារអង្គភាពទូរគមនាគមន៍កម្ពុជា (T.C) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ឆ្នាំង, ក្រចេះ, ស្ទឹងត្រែង និងព្រះវិហារ ។

៦- លោកជំទាវ **ប្រាក់ ច័ន្ទណាយ** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីការត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ និងកិច្ចការយេនឌ័រ (Gender) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍រាជធានីភ្នំពេញ, ខេត្តកំពង់ស្ពឺ, ព្រះសីហនុ និងកោះកុង ។

**អនុរដ្ឋលេខាធិការ ៖**

១- ឯកឧត្តម **ទី ចន** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការងារសម្របសម្រួលកិច្ចការនីតិកម្ម, ការងាររបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា (T.R.C) និងទំនាក់ទំនងអន្តរជាតិលើវិស័យប្រៃសណីយ៍, ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកំពង់ធំ, សៀមរាប, បន្ទាយមានជ័យ និងមណ្ឌលគីរី ។

២- ឯកឧត្តម **ភុយ ពុំ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការងាររដ្ឋបាល, បុគ្គលិក និងបណ្តុះបណ្តាល ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍រាជធានីភ្នំពេញ, ខេត្តកំពង់ស្ពឺ, ព្រះសីហនុ និងកោះកុង ។

៣- ឯកឧត្តម **មាស ម៉ុ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារសហប្រតិបត្តិការអន្តរជាតិ និងការងាររបស់អង្គភាពទូរគមនាគមន៍កម្ពុជា (T.C) ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង, ព្រះវិហារ, កំពង់ឆ្នាំង និងក្រចេះ ។

៤- ឯកឧត្តម **ចាយ ណារ៉ុធ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារគោលនយោបាយអភិវឌ្ឍវិស័យប្រៃសណីយ៍, សវនកម្មផ្ទៃក្នុង ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន និងឧត្តរមានជ័យ ។

៥- លោកជំទាវ **ទ្រឹង មុន្នីរតនៈ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលកិច្ចការគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍, ភាពប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍ និងយែនឌ័រ (Gender) ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល, តាកែវ, កំពត និងកែប ។

៦- ឯកឧត្តម **អេ សុភា** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងាររបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (D.M.C) និងអធិការកិច្ច។

៧- ឯកឧត្តម **ខុង មករា** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារផែនការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, កម្មវិធីវិនិយោគសាធារណៈ (P.I.P), ការងារសហប្រតិបត្តិការអន្តរជាតិខាងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(I.C.T) ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម, ព្រៃវែង, ស្វាយរៀង និងរតនគីរី ។

**ប្រការ ៣ ៖** រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ អាចទទួលបន្ទុកការងារបន្ថែមមួយចំនួនទៀតតាមការចាំបាច់ដែលរដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៤ ៖** សេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ ៖** រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ទ្រាក់ សុខុន**

__កន្លែងទទួល ៖__

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី

-ដូចប្រការ ៥

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ